# សៀវភៅណែនាំ
# មិត្តកសិករ

កម្រិត ១.០ | ២០២១

មិត្តកសិករ

# មាតិកា


## សេចក្តីផ្តើម ៤

**បរិការណ៍** ៤

**ទិដ្ឋភាពរួមនៃ សៀវភៅណែនាំអំពីគំរូមិត្តកសិករសម្រាប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ៥

## ដំណាក់កាល ទី១៖ កំណត់អត្តសញ្ញាណកសិករសក្តានុពល ៨

ជំហាន ទី១ ៖ កំណត់ភូមិឃុំគោលដៅ ៨

ជំហាន ទី២ ៖ ទាក់ទងមេឃុំ មេភូមិយកព័ត៌មាន ៨

ជំហាន ទី៣ ៖ សម្ភាសកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលមានសក្តានុពល ៨

ជំហាន ទី៤ ៖ បញ្ចូលព័ត៌មានក្នុងប្រព័ន្ធទិន្នន័យ ៨

## ដំណាក់កាល ទី២៖ ជំនួបបង្កើតតម្រូវការ ១២

ជំហាន ទី១៖ ត្រៀមសម្រាប់ជំនួបបង្កើតតម្រូវការ ១៣

ជំហាន ទី២៖ ទាក់ទងឱ្យក្រុមហ៊ុនឯកជនចូលរួមជំនួបបង្កើតតម្រូវការ ១៣

ជំហាន ទី៣៖ អញ្ជើញកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលមានសក្តានុពលឱ្យមកចូលរួម ១៣

ជំហាន ទី៤៖ ដំណើរការជំនួបបង្កើតតម្រូវការ ១៣

ជំហាន ទី៥៖ ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល ១៣

ជំហាន ទី៦៖ កត់ត្រាទិន្នន័យកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករចូលក្នុងប្រព័ន្ធទិន្នន័យ ១៣

ជំហាន ទី៧៖ កំណត់អត្តសញ្ញាណកសិករនិងសេវាករនាំមុខ ១៣

ជំហាន ទី៨៖ ទាក់ទងក្រុមហ៊ុនដើម្បីផ្តល់សេវាឱ្យកសិករឬសេវាករនាំមុខ ១៣

## ដំណាក់កាល ទី៣៖ កិច្ចបង្ហាញនៅទីវាល ១៧

ជំហាន ទី១៖ ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខម្នាក់ ១៨

ជំហាន ទី២៖ កំណត់ថ្ងៃកម្មវិធី ១៨

ជំហាន ទី៣៖ សម្របសម្រួលប្រុងប្រៀបគ្រឿងយន្ត ១៨

ជំហាន ទី៤៖ អញ្ជើញកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលមានចំណាប់អារម្មណ៍ ៦០នាក់ ១៨

ជំហាន ទី៥៖ រៀបចំទីតាំងត្រៀមសម្រាប់កម្មវិធី ១៨

ជំហាន ទី៦៖ ដំណើរការកិច្ចបង្ហាញតាមដំណាក់កាលកសិកម្មអភិរក្ស ១៨

ជំហាន ទី៧៖ ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល ១៨

ជំហាន ទី៨៖ កត់ត្រាទិន្នន័យកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករចូលក្នុងប្រព័ន្ធទិន្នន័យ ១៨

ជំហាន ទី៩៖ ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករតាមមធ្យោបាយទាក់ទងនានា ១៨

មិត្តកសិករ


## ដំណាក់កាល ទី៤៖ កិច្ចបង្ហាញពាណិជ្ជកម្ម ២២

ជំហាន ទី១៖ ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខជោគជ័យម្នាក់ ២៣
ជំហាន ទី២៖ កំណត់ថ្ងៃកម្មវិធី ២៣
ជំហាន ទី៣៖ សម្របសម្រួលប្រុងប្រៀបគ្រឿងយន្ត ២៣
ជំហាន ទី៤៖ អញ្ជើញកសិករថ្មី ១៤០នាក់ ២៣
ជំហាន ទី៥៖ រៀបចំទីតាំងនិងត្រៀមលំដាប់លំដោយសម្រាប់កម្មវិធី ២៣
ជំហាន ទី៦៖ ដំណើរការកិច្ចបង្ហាញទ្រង់ទ្រាយធំ ២៣
ជំហាន ទី៧៖ ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល ២៣

## ដំណាក់កាល ទី៥៖ កិច្ចប្រជុំប្រចាំឆ្នាំ ២៧

ជំហាន ទី១៖ កំណត់អត្តសញ្ញាណក្រុមហ៊ុនមានសក្តានុពល ២៧
ជំហាន ទី២៖ អញ្ជើញក្រុមហ៊ុនធ្វើទស្សនកិច្ច ២៧

## ដំណាក់កាល ទី៦៖ ជំនួបផ្សព្វផ្សាយជាមួយវិស័យឯកជន ៣០

ជំហាន ទី១៖ កំណត់អត្តសញ្ញាណក្រុមហ៊ុនមានសក្តានុពល ៣០
ជំហាន ទី២៖ អញ្ជើញក្រុមហ៊ុនធ្វើទស្សនកិច្ច ៣០

## ឧបសម្ព័ន្ធ

ឯកសារគាំទ្រ ទី១៖ បញ្ជីសំណួរសម្រាប់សួរមេឃុំ មេភូមិ ៣៣
ឯកសារគាំទ្រ ទី២៖ បញ្ជីសំណួរសម្រាប់សម្ភាសកសិករ(ឬសហគមន៍កសិកម្ម) ៣៤
ឯកសារគាំទ្រ ទី៣៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញស្តីពីកសិកម្មអភិរក្ស ៣៦
ឯកសារគាំទ្រ ទី៤៖ មធ្យោបាយទាក់ទងសម្រាប់ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករ ៣៧
ឯកសារគាំទ្រ ទី៥៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំ ៣៨

# សេចក្ដីផ្ដើម

## បរិការណ៍

ចាប់តាំងពីឆ្នាំ២០០៤ មក ប្រព័ន្ធនិងវិធីសាស្ត្រដាំដុះប្រកបដោយនវានុវត្តន៍ផ្អែកលើគោលការណ៍នៃកសិកម្មអភិរក្ស ត្រូវបានដំឡើងនិងសាកល្បងក្នុងប្រព័ន្ធកេ្សត្របរិស្ថានមួយចំនួននៅក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវបែបវិទ្យាសាស្ត្រទាំងនេះបង្ហាញថាប្រព័ន្ធដាំដុះបែបកសិកម្មអភិរក្ស (Conservation Agriculture Production Systems – CAPS) បង្កើនភាពមានជីជាតិរបស់ដី កាត់បន្ថយតម្រូវការកម្លាំងពលកម្ម សន្សំសំចៃទឹក ព្រមទាំងបង្កើនទិន្នផលនិងប្រាក់ចំណូលរបស់កសិករខ្នាតតូច។ ក៏ប៉ុន្តែ ដើម្បីឱ្យទម្លាប់ដាំដុះកែប្រែជាយូរអង្វែងទៅ ចាំបាច់ត្រូវជំរុញឱ្យខាងក្រុមហ៊ុនឯកជនចូលរួមគាំទ្រប្រព័ន្ធនិងវិធីសាស្ត្រដាំដុះបែបថ្មីនេះ ព្រោះថាក្រុមហ៊ុនឯកជនដើរតួយ៉ាងសំខាន់ក្នុងការនាំចូលនិងចែកចាយបច្ចេកវិទ្យាថ្មីៗ ការណែនាំកសិករអំពីរបៀបប្រើប្រាស់ និងការផ្ដល់ព័ត៌មានចាំបាច់នានាទៅតាមច្រវ៉ាក់ផលិតកម្មនៃមុខដំណាំនីមួយៗ។ ដើម្បីបង្កើនការទទួលយកប្រព័ន្ធនិងវិធីសាស្ត្រដាំដុះបែបកសិកម្មអភិរក្សផង និងដើម្បីបង្កើនភាពធន់នឹងបម្រែបម្រួលអាកាសធាតុនិងការប្រែប្រួលគំហុកនៃទីផ្សារផង មុខព្រួញសំខាន់ពីរដែលត្រូវផ្ដោតគឺការបញ្ជ្រាបការប្រើប្រាស់គ្រឿងយន្តនិងបច្ចេកវិទ្យាកសិកម្មថ្មីៗមួយ និងភាពងាយស្វែងរកនិងទទួលបាននូវពូជដំណាំសម្បូរបែបមួយ។

ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ កម្មវិធីកំណើនប្រកបដោយបរិយាប័ន្ននិងនវានុវត្តន៍នៃតំបន់មេគង្គ (Mekong Inclusive Growth and Innovation Programme – MIGIP) និងគម្រោងសេវាកសិកម្មអភិរក្សដោយគិតកម្រៃ (Conservation Agriculture with a Fee – CASF) បានសហការគ្នាអនុវត្តគម្រោងមួយហៅថា «មិត្តកសិករ» នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដើម្បីផ្សព្វផ្សាយនិងជំរុញឱ្យកសិករទទួលយកកសិកម្មអភិរក្សទៅអនុវត្ត។ ក្រុមការងារបានធ្វើការជិតស្និទ្ធជាមួយនឹងកសិករនិងសេវាករនៅតាមទីតាំងគោលដៅ ដោយមានការចូលរួមជាមួយនឹងក្រុមហ៊ុនឯកជនផង ដើម្បីជំរុញការទទួលយកកសិកម្មអភិរក្ស។ គម្រោងនេះបានក្លាយជាគំរូការផ្សព្វផ្សាយអំពីកសិកម្មអភិរក្សដ៏ជោគជ័យនិងមានប្រសិទ្ធភាពនៅកម្ពុជា។

យ៉ាងនេះក្ដី គំរូនេះមានចំណុចមួយចំនួនដែលគួរកែលម្អបន្ថែម។ ទីមួយ សកម្មភាពបច្ចុប្បន្នលាតសន្ធឹងត្រឹមរយៈពេលមួយគម្រោង និងត្រូវការកែច្នៃបន្ថែមដើម្បីធានានិរន្តរភាព។ ទីពីរ មានការខ្វះខាតខ្លះផ្នែកធនធានមនុស្សបច្ចេកទេស។ ទីបី ការចូលរួមនិងសហការជាមួយនឹងក្រុមហ៊ុនឯកជននៅមានកម្រិតនៅឡើយ។ ចុងក្រោយ ទីបួន ទោះជាបានជោគជ័យហើយក្ដី គម្រោងនេះនៅមិនទាន់បានសម្របបញ្ចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្មផ្លូវការរបស់រាជរដ្ឋាភិបាលនៅឡើយ។

ឆ្លើយតបនឹងចំណុចគួរកែលម្អខាងលើ កំណែថ្មីនៃ «គំរូមិត្តកសិករ» បន្តការផ្សព្វផ្សាយកសិកម្មអភិរក្ស ដោយផ្ដោតលើកិច្ចសហការជិតស្និទ្ធជាមួយនឹងដៃគូចម្រុះ។ ដៃគូទាំងនេះរួមមាន នាយកដ្ឋានបីនៅថ្នាក់ជាតិ (នាយកដ្ឋានវិស្វកម្មកសិកម្ម នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) រដ្ឋបាលខេត្ត និងក្រុមហ៊ុនឯកជននានាជាដៃគូវិស័យឯកជន។ ដៃគូទាំងនេះជួយជ្រោមជ្រែងចលកររចម្បងគឺមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មន្ទីរ ក.ស.ក.) នៅទីតាំងគោលដៅ ដើម្បីផ្សព្វផ្សាយកសិកម្មអភិរក្សឱ្យដល់កសិករខ្នាតតូចដោយជោគជ័យ (សូមមើលរូបលេខ១)។

នាយកដ្ឋានថ្នាក់ជាតិទាំងបីដើរតួសំខាន់ក្នុងការផ្ទេរចំណេះដឹងបច្ចេកទេសពាក់ព័ន្ធនឹងកសិកម្មអភិរក្សទៅតាមមុខជំនាញរៀងៗខ្លួន ឱ្យទៅមន្ទីរក.ស.ក.។ កាលណាទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ហើយ មន្ទីរក.ស.ក. នឹងធ្វើការជាមួយនឹងដៃគូឯកជនដើម្បីផ្សព្វផ្សាយអំពីកសិកម្មអភិរក្សទៅកាន់សហគមន៍កសិកម្ម សេវាករ និង «កសិករនាំមុខ» ដែលសុទ្ធសឹងជាក្រុមគោលដៅដែលនឹងផ្សព្វផ្សាយកសិកម្មអភិរក្សបន្តឱ្យទៅដល់កសិករខ្នាតតូចចំនួនច្រើន។ ក្រោយពេលបណ្ដុះបណ្ដាលនេះដែរ នាយកដ្ឋានថ្នាក់ជាតិទាំងបីក្លាយជា «ទីប្រឹក្សា» ដែលជួយផ្ដល់យោបល់ដល់មន្ទីរក.ស.ក. តាមសំណើជាក់ស្ដែង។

នៅក្នុងដំណាក់កាលអនុវត្តឆ្នាំ២០២១-២០២៤ អង្គការស្វីសខនថាក់ (Swisscontact) និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) នឹងផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុចាំបាច់ដើម្បីអនុវត្តគំរូមិត្តកសិករថ្មីនេះនៅខេត្តបាត់ដំបងនិងខេត្តព្រះវិហារ។ ការអនុវត្តគំរូមិត្តកសិករពិតជាមានសារៈសំខាន់ណាស់ ព្រោះថានៅពេលអនុវត្តបានជោគជ័យ គំរូនេះជាចលករជួយឱ្យប្រព័ន្ធផ្សព្វផ្សាយកសិកម្មផ្លូវការរបស់រដ្ឋអាចផ្សព្វផ្សាយកសិកម្មអភិរក្សក្នុងប្រទេសកម្ពុជាបានយូរអង្វែងទៅមុខ ដោយមានការចូលរួមពីដៃគូឯកជន បើទុកជាពុំមានអង្គការស្ថាប័នខាងក្រៅចូលរួមក្តី។




រូបលេខ១៖ទិដ្ឋភាពរួមនៃគំរូមិត្តកសិករបង្ហាញអំពីលំហូរព័ត៌មានបច្ចេកទេសទៅកាន់កសិករខ្នាតតូច។

## ទិដ្ឋភាពរួមនៃសៀវភៅណែនាំអំពីគំរូមិត្តកសិករសម្រាប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សៀវភៅណែនាំមិត្តកសិករនេះ មានគោលការណ៍ណែនាំដើម្បីជួយឱ្យមន្ទីរក.ស.ក. អនុវត្តគំរូមិត្តកសិករនៅតាមភូមិសាស្ត្រគោលដៅ។ គោលការណ៍ណែនាំទាំងនេះចែកចេញជា ៦ដំណាក់កាលគឺ (១) កំណត់អត្តសញ្ញាណ (២) ជំនួបបង្កើតតម្រូវការ (៣) កិច្ចបង្ហាញនៅទីវាល (៤) កិច្ចបង្ហាញពាណិជ្ជកម្ម (៥) កិច្ចប្រជុំប្រចាំឆ្នាំ និង (៦) ជំនួបផ្សព្វផ្សាយជាមួយវិស័យឯកជន។ គួរកត់សម្គាល់ថា ការចូលរួមរបស់នាយកដ្ឋានថ្នាក់ជាតិនិងរដ្ឋបាលខេត្តជាគន្លឹះទាំងក្នុងការអនុវត្តគម្រោងរបស់ MIGIP និងនៅក្នុងរូបលេខ១ តែយ៉ាងនេះក្តី សៀវភៅណែនាំនេះកាត់យកតែផ្នែកដែលមន្ទីរក.ស.ក. ត្រូវសហការជាមួយនឹងដៃគូឯកជននិងកសិករនិងសេវាករនាំមុខ មកពិស្តារប៉ុណ្ណោះ។

ខ្លឹមសារណែនាំមានរាយតាមដំណាក់កាលនីមួយៗដើម្បីងាយអាន ហើយដំណាក់កាលនីមួយៗបែងចែកជាជំហានលម្អិតទៅតាមលំដាប់លំដោយជារួមនៃសកម្មភាព។ បន្ថែមលើនេះមានខ្លឹមសារណែនាំទៅតាមជំហាននីមួយៗព្រមទាំងឯកសារគាំទ្រតាមជាក់ស្តែងដើម្បីឱ្យការអនុវត្តគំរូនេះកាន់តែមានភាពសុក្រឹត។

## អ្នកនិពន្ធ៖

ផាន់ រតនវិទ្យា, អ៊ាង ដាវីត, ស្រូ សោគន្ធិកា, សេង តារាបណ្ឌិត

អ្នកផ្តល់ប្រឹក្សា៖ Rajiv Pradhan

## គាំទ្រដោយ៖

ស វេង, សួស វុទ្ធី, សេន រស្មី, សន សុវណ្ណដា, ហុក លីដា, ថេង ឪណា, ឡោ លីត្តួ, គង់ វ៉ាដា, ម៉ៅ មីនា, ហេង ជូឡុង, ងិន កុសល, សេង វ៉ាង, Manny  Reyes, អឿ វារីដា

## បុព្វកថា

សៀវភៅគំរូណែនាំមួយត្រូវបានរៀបចំដោយ នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម, នាយកដ្ឋានវិស្វកម្មកសិកម្ម, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រុមហ៊ុនស្មាតអាក្រូ, វិទ្យាស្ថានស្រាវជ្រាវស៊ីរ៉ាត (CIRAD), អង្គការស្វីសខនថាក់ (Swisscontact), មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ (CE SAIN), មហាវិទ្យាល័យវិស្វកម្មកសិកម្មនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម និងត្រូវបានផ្តល់ជំនួយមូលនិធិទាំងស្រុង និងមួយផ្នែកដោយ គម្រោងនវានុវត្តន៍សំរាប់កសិកម្មប្រកបដោយនិរន្តរភាព(ISA) ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយមូលនិធិ Happel, Marcuard Family Office និងម្ចាស់ជំនួយផ្សេងទៀត ហើយគម្រោងនេះ ក៏ជាកម្មវិធីអភិវឌ្ឍន៍មួយរបស់អង្គការស្វីសខនថាក់ (Swisscontact) ដែលត្រូវបានផ្តល់សហហិរញ្ញប្បទានពី ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការស្វីស (SDC) និង ក្រសួងការបរទេសនៃសហព័ន្ធស្វីស (FDFA), សកលវិទ្យាល័យ Kansas State , មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ (CE SAIN) តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ការិយាល័យសំរាប់ភាពធន់និងសន្តិសុខស្បៀង/មជ្ឈមណ្ឌលសំរាប់ការលូតលាស់តាមរយៈកសិកម្ម ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការ

# AID-OAA-L-14-00006 ដែលជាផ្នែកមួយនៃកម្មវិធី Feed the Future Innovation Lab for Collaborative Research on Sustainable Intensification (SIIL), គម្រោងគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរអេកូឡូស៊ីកសិកម្មសំរាប់ប្រទេសកម្ពុជា (WAT4CAM) ដែលត្រូវបានផ្តល់ជំនួយមូលនិធិដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង និងសហភាពអឺរ៉ុប (កិច្ចព្រមព្រៀង WAT4CAM-CS/04-02)។ រាល់យោបល់ ការរកឃើញ សេចក្តីសន្និដ្ឋាន ឬអនុសាសន៍ដែលបានបង្ហាញនៅទីនេះគឺជារបស់អ្នកនិពន្ធប៉ុណ្ណោះ៉។

## អ្នករចនា

ស៊ុក សោភ័ណ្ឌ និង អឿ វារីដា ក្រុមការងារផ្នែកទំនាក់ទំនងនៃស្វីសខនថាក់



មិត្តកសិករ

# ដំណាក់កាល ទី១

# កំណត់អត្តសញ្ញាណ កសិករសក្តានុពល

# ដ ០១ កំណត់អត្តសញ្ញាណកសិករសក្តានុពល

មិត្តកសិករ

ដំណាក់កាលទីមួយនេះគឺជាការកំណត់អត្តសញ្ញាណកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលសមស្រប ឱ្យក្រុមការងាររបស់មន្ទីរក.ស.ក. ផ្សព្វផ្សាយកសិកម្មអភិរក្សទៅ, ដោយចាប់ផ្តើមពីការកំណត់ឃុំនិងភូមិគោលដៅ។
ដំណាក់កាលទីមួយនេះគឺជាការកំណត់អត្តសញ្ញាណកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលសមស្រប ឱ្យក្រុមការងាររបស់មន្ទីរក.ស.ក. ផ្សព្វផ្សាយកសិកម្មអភិរក្សទៅ, ដោយចាប់ផ្តើមពីការកំណត់ឃុំនិងភូមិគោលដៅ។

## គោលបំណង

ដើម្បីកំណត់ក្រុមកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករ ដែលត្រូវអញ្ជើញចូលរួមជំនួបបង្កើតតម្រូវការ។

## ជំហាន

| | ជំហាន | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | កំណត់ភូមិឃុំគោលដៅ | ដើម្បីកំណត់ភូមិឃុំដែលសមស្រប នឹងទទួលយកកសិកម្មអភិរក្ស | បញ្ជីភូមិឃុំមានសក្តានុពល |
| ២ | ទាក់ទងមេឃុំ មេភូមិ យកព័ត៌មាន | ដើម្បីប្រមូលឈ្មោះកសិករ(ឬសហគមន៍កសិកម្ម)/សេវាករមានសក្តានុពល ព្រមជាមួយព័ត៌មានពាក់ព័ន្ធ | បញ្ជីឈ្មោះកសិករ(ឬសហគមន៍កសិកម្ម)/សេវាករមានសក្តានុពល រួមទាំងព័ត៌មានពួកគាត់ |
| ៣ | សម្ភាសកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលមានសក្តានុពល | ដើម្បីកំណត់រកកសិករ(ឬសហគមន៍កសិកម្ម)/សេវាករដែលគួរអញ្ជើញចូលរួមជំនួបបង្កើតតម្រូវការ | ទម្រង់ព័ត៌មានកសិករ(ឬសហគមន៍កសិកម្ម)/សេវាករដែលបានសម្ភាស |
| ៤ | បញ្ចូលព័ត៌មានក្នុងប្រព័ន្ធទិន្នន័យ | ដើម្បីកំណត់រកកសិករ(ឬសហគមន៍កសិកម្ម)/សេវាករដែលគួរអញ្ជើញចូលរួមជំនួបបង្កើតតម្រូវការ | សំណុំទិន្នន័យកសិករ(ឬសហគមន៍កសិកម្ម)/សេវាករមានសក្តានុពល |

មិត្តកសិករ

# សេចក្តីណែនាំលើជំហាននីមួយៗ

## ១. កំណត់ភូមិឃុំគោលដៅ

ការកំណត់ភូមិឃុំសមស្របមានសារៈសំខាន់ណាស់ក្នុងការចាប់ផ្តើមផ្សព្វផ្សាយកសិកម្មអភិរក្ស។ កសិកម្មអភិរក្សសមស្របសម្រាប់ទីដាំដុះនៅដីទំនាបក្តី ដីទួលក្តី ដែលខ្សោះជីជាតិនិងមានផលិតភាពទាប ព្រមទាំងប្រឈមនឹងការហូរច្រោះដីនិងប្រភពទឹកមិនគ្រប់គ្រាន់។ គប្បីជ្រើសរើសយកភូមិឃុំណាដែលត្រូវការបច្ចេកវិទ្យាថ្មីនេះជាកន្លែងចាប់ផ្តើម។

## ២. ទាក់ទងមេឃុំ មេភូមិយកព័ត៌មាន

ក្រោយពីសម្គាល់បាននូវភូមិឃុំគោលដៅហើយ គេអាចរៀបចំជួបជាមួយនឹងមេឃុំនិងមេភូមិគោលដៅដើម្បីសុំឬធ្វើបញ្ជីឈ្មោះកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករក្នុងភូមិឃុំនោះ និងសាកសួរព័ត៌មាននានារបស់ឃុំឬភូមិទាំងមូលផង (ដូចជាទំហំដីដាំដុះនិងប្រភេទដំណាំជាអាទិ៍) និងព័ត៌មានរបស់កសិករ/សេវាកម្នាក់ៗផង (ឯកសារគាំទ្រទី១)។ តាមព័ត៌មានដែលប្រមូលបានមកនេះ អាចពិចារណាថាកសិករណាឬសេវាករណាដែលត្រូវសម្ភាស។

## ៣. សម្ភាសកសិករនិងសេវាករដែលមានសក្តានុពល

ក្នុងជំហាននេះ ក្រុមការងាររបស់មន្ទីរគួរជួបកសិករ(ឬសហគមន៍កសិកម្ម)/សេវាករដែលត្រូវសម្ភាសម្តងម្នាក់ដើម្បីសុំសួរព័ត៌មានរបស់ពួកគាត់។ ព័ត៌មានដែលត្រូវប្រមូលគឺពាក់ព័ន្ធនឹងផ្ទៃដីដាំដុះ ប្រភេទដំណាំ ឬទំហំប្រតិបត្តិការនៃការដាំដុះឬជួលគ្រឿងយន្តរបស់គាត់ (ឯកសារគាំទ្រទី២ និងទី៣)។

## ៤. បញ្ចូលព័ត៌មានក្នុងប្រព័ន្ធទិន្នន័យ

ដើម្បីរក្សាព័ត៌មានទុកឱ្យមានរបៀបរៀបរយសម្រាប់ប្រើប្រាស់នៅពេលក្រោយ សូមបញ្ចូលព័ត៌មានដែលប្រមូលបានពីជំហានទី២និងទី៣ទៅក្នុងប្រព័ន្ធទិន្នន័យ (ឯកសារគាំទ្រទី៤)។

## Tips គន្លឹះ

- គួរជួបជាមួយនឹងមេឃុំ មេភូមិផ្ទាល់មុខ។
- ប្រើបញ្ជីឈ្មោះកសិករនិងសេវាករដើម្បីសម្រេចថាកសិករ (ឬសហគមន៍កសិកម្ម) /សេវាករណាគួរសម្ភាស។
- នៅពេលសម្ភាស អាចប្រើការពន្យល់បែបសង្ខេបអំពីគុណប្រយោជន៍នៃកសិកម្មអភិរក្សក្នុងការដោះស្រាយតំហាយគុណភាពដី ជាវិធីសាស្ត្រស្ទាបស្ទង់ចំណាប់អារម្មណ៍របស់អ្នកផ្តល់សម្ភាសក្នុងការទទួលយកកសិកម្មអភិរក្ស។
- ឧទាហរណ៍លក្ខណៈសេវាករដែលគួរទាក់ទងឱ្យចូលរួម៖ (១) សេវាករដែលយកចិត្តទុកដាក់យ៉ាងសកម្មក្នុងមុខរបររបស់គាត់ (២) សេវាករដែលមានគ្រឿងយន្តបញ្ឈរចោល (រកភ្ញៀវមិនបាន) និង (៣) កសិករដែលមានដីដាំដុះធំ មានគ្រឿងយន្តខ្លួនឯង តែក៏ជួលគ្រឿងយន្តនោះឱ្យទៅអ្នកនៅភូមិ ឃុំជាមួយគ្នា។

## Tool ឯកសារ

- ឯកសារគាំទ្រ ទី១៖ បញ្ជីសំណួរសម្រាប់សួរមេឃុំ មេភូមិ។
- ឯកសារគាំទ្រ ទី២៖ បញ្ជីសំណួរសម្រាប់សម្ភាសកសិករមានសក្តានុពល។
- ឯកសារគាំទ្រ ទី៣៖ បញ្ជីសំណួរសម្រាប់សម្ភាសសេវាករមានសក្តានុពល។



មិត្តកសិករ

# ដំណាក់កាល ទី២

# ជំនួបបង្កើតតម្រូវការ

# ៤ ០២ ជំនួបបង្កើតតម្រូវការ

ដំណាក់កាលនេះផ្តោតលើការជួបជាមួយនឹងកសិករនិងសេវាករមានសក្តានុពលដើម្បីពន្យល់អំពីកសិកម្មអភិវិក្ស និងស្វែងយល់ឱ្យបានច្បាស់អំពីចំណាប់អារម្មណ៍របស់ពួកគាត់ក្នុងការអនុវត្តនិងចំណាយទុនលើកសិកម្មអភិរក្ស។ ជំនួបបង្កើតតម្រូវការនេះ គួរធ្វើឡើងជាពីរលើកផ្សេងគ្នា លើកទីមួយជួបតែជាមួយនឹងសេវាករដើម្បីបង្ហាញឱកាសអាជីវកម្មពាក់ព័ន្ធនឹងកសិកម្មអភិរក្ស។ ឯលើកទីពីរ នៅថ្ងៃផ្សេងមួយទៀត មានទាំងកសិករនិងសេវាករចូលរួមដើម្បីឱ្យកសិករស្វែងយល់អំពីគុណប្រយោជន៍នៃកសិកម្មអភិរក្ស ទន្ទឹមនឹងឱ្យសេវាករឃើញអំពីទំហំតម្រូវការសេវាកម្មកសិកម្មអភិរក្សដែលនឹងមានក្នុងតំបន់របស់គាត់។ ធ្វើដូច្នេះ ជំនួបបង្កើតតម្រូវការនឹងឈានទៅផ្សារភ្ជាប់ការផ្គត់ផ្គង់ (ខាងសេវាករ) និងតម្រូវការ (ខាងកសិករ) ដែលនឹងអនុញ្ញាតឱ្យកសិកម្មអភិរក្សអាចដំណើរការទៅបានដោយពុំសូវមានបញ្ហាចោទផ្នែកខាងគ្រឿងយន្ត។ នៅចុងដំណាក់កាលនេះ យើងចង់ឃើញកសិករមួយចំនួនទោះពីរបីរូបក្តី ចាប់អារម្មណ៍សាកល្បងទទួលសេវាកសិកម្មអភិរក្ស ដែលជាចំណុចចាប់ផ្តើមចាំបាច់សម្រាប់ដំណាក់កាលបន្តបន្ទាប់។

## គោលបំណង

ដើម្បីណែនាំឱ្យកសិករ (ឬសហគមន៍កសិកម្ម) និងសេវាករស្គាល់អំពីកសិកម្មអភិរក្ស ព្រមទាំងរៀបចំឱ្យកសិករដែលមានបំណងចង់ទទួលសេវាកសិកម្មអភិរក្ស បានទទួលសេវានោះ។

មិត្តកសិករ

# ជំហាន

| | ជំហាន | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | ត្រៀមសម្រាប់ជំនួបបង្ហើតតម្រូវការ | ដើម្បីមានទីតាំងសមស្របនិងដែលរៀបចំបានត្រឹមត្រូវសម្រាប់ផ្សព្វផ្សាយអំពីកសិកម្មអភិរក្សរហូតទទួលបានកសិករនាំមុខ | ម្ចាស់ទីតាំងព្រមព្រៀងឱ្យទីតាំងរៀបចំកម្មវិធី។ |
| ២ | ទាក់ទងឱ្យក្រុមហ៊ុនឯកជនចូលរួមជំនួបបង្កើតតម្រូវការ | ម្ចាស់ទីតាំងព្រមព្រៀងឱ្យទីតាំងរៀបចំកម្មវិធី។ | ក្រុមហ៊ុនបញ្ជាក់ការចូលរួមនិងបានត្រៀមគ្រឿងយន្ត។ |
| ៣ | អញ្ជើញកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករដែលមានសក្តានុពលឱ្យមកចូលរួម | ដើម្បីឱ្យពួកគាត់ចូលរួមជំនួបបង្កើតតម្រូវការ | សេវាករមានសក្តានុពលនិងកសិករ(ឬសហគមន៍កសិកម្ម)នៅក្បែរនោះត្រូវបានអញ្ជើញ។ |
| ៤ | ដំណើរការជំនួបបង្កើតតម្រូវការ | ដើម្បីជំរុញឱ្យកសិករមានសក្តានុពលប្រើសេវាកសិកម្មអភិរក្សនិងជំរុញឱ្យសេវាករពិចារណាចំណាយទុនលើគ្រឿងយន្តកសិកម្មអភិរក្ស | កសិករមួយចំនួនមានបំណងឬសម្រេចប្រើសេវាកសិកម្មអភិរក្ស។ |
| ៥ | ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល | ដើម្បីផ្តល់ឱកាសឱ្យក្រុមហ៊ុនផ្សព្វផ្សាយផលិតផលរបស់ខ្លួនទៅកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករ | សេវាករបានឃើញផលិតផលសម្រាប់កសិកម្មអភិរក្សនិងបានជួបតំណាងក្រុមហ៊ុន។ |
| ៦ | កត់ត្រាទិន្នន័យកសិករ (ឬសហគមន៍កសិកម្ម)និងសេវាករចូលក្នុងប្រព័ន្ធទិន្នន័យ | ដើម្បីកត់ត្រាការប្រែប្រួលឥរិយាបថលើការទទួលយកកសិកម្មអភិរក្ស, និងចុះឈ្មោះអ្នកចូលរួមថ្មី | ព័ត៌មានកសិករ(ឬសហគមន៍កសិកម្ម)/សេវាករ ទាំងចាស់ទាំងថ្មីត្រូវបានកត់ត្រា។ |
| ៧ | កំណត់អត្តសញ្ញាណកសិករនិងសេវាករនាំមុខ | ដើម្បីស្វែងរកថាកសិករ/សេវាករណាមានបំណងប្រើសេវាឬចំណាយទុនលើគ្រឿងយន្តកសិកម្មអភិរក្ស | បញ្ជីកសិករ/សេវាករនាំមុខ |
| ៨ | ទាក់ទងក្រុមហ៊ុនដើម្បីផ្តល់សេវាឱ្យកសិករឬសេវាករនាំមុខ | ដើម្បីធានាថាក្រុមហ៊ុនផ្តល់សេវាដល់កសិករនាំមុខ | កសិករនាំមុខទទួលបានសេវាកសិកម្មអភិរក្ស។ |

មិត្តកសិករ

# សេចក្តីណែនាំលើជំហាននីមួយៗ

## ១. ត្រៀមសម្រាប់ជំនួបបង្កើតតម្រូវការ

ក. ទីតាំង៖ ការជ្រើសរើសទីតាំងសមស្របជាកត្តាចាំបាច់សម្រាប់ជំនួបបង្កើតតម្រូវការ។ ប្រសិនបើភូមិសាស្ត្រនោះមានកសិករដែលកំពុងអនុវត្តកសិកម្មអភិរក្សបានលទ្ធផលល្អ ហើយអាចរៀបចំនៅទីតាំងរបស់កសិករនោះបាន គួររៀបចំនៅទីនោះ ព្រោះម្ចាស់ទីតាំងនោះនឹងអាចលើកអំពីបទពិសោធជោគជ័យរបស់គាត់មកចែករំលែក ហើយអាចឱ្យអ្នកចូលរួមកាន់តែងាយទទួលយកកសិកម្មអភិរក្សទៅអនុវត្ត។ ប្រសិនបើភូមិសាស្ត្រនោះគ្មានកសិករដែលកំពុងអនុវត្តកសិកម្មអភិរក្សទេនោះ ក្រុមការងារមន្ទីរគួរស្វែងរកដីដាំដុះណាដែលស្អាតនិងមានផ្ទៃស្មើល្អ (សម្រាប់សម្រួលដល់ការបង្ហាញអំពីគ្រឿងយន្ត) ហើយដែលមានទីតាំងនៅលើផ្លូវរួមមួយក្នុងភូមិសាស្ត្រគោលដៅនោះ (ដើម្បីអ្នកចូលរួមងាយស្រួលទៅមក) ដើម្បីរៀបចំកម្មវិធី។

ខ. ការរៀបចំទីតាំង៖ មុនថ្ងៃកម្មវិធី ទីតាំងដែលបានជ្រើសរើស ត្រូវរៀបចំឱ្យបានសមរម្យសម្រាប់គោលបំណងសំខាន់ៗនៃកម្មវិធី ពោលគឺត្រូវមានពីរផ្នែកធំៗ។ មួយផ្នែកជាទីវាលឬទីដាំដុះ សម្រាប់បង្ហាញសមត្ថភាពគ្រឿងយន្ត មួយផ្នែកទៀតមានម្លប់ (ឧទា. រោង) និងកៅអីសម្រាប់ធ្វើបទបង្ហាញអំពីកសិកម្មអភិរក្ស ជូនអ្នកចូលរួម។ ប្រសិនបើអាច គួរមានអាហារសម្រន់ផង។

គ. បទបង្ហាញ៖ ត្រូវរៀបចំបទបង្ហាញងាយយល់ សម្រាប់អ្នកចូលរួមជំនួបបង្កើតតម្រូវការនេះ។

## ២. ទាក់ទងឱ្យក្រុមហ៊ុនឯកជនចូលរួមជំនួបបង្កើតតម្រូវការ

ក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធរួមមានក្រុមហ៊ុនលក់គ្រឿងយន្តសម្រាប់កសិកម្មអភិរក្សនិងក្រុមហ៊ុនលក់ដំណាំគម្របដីសម្រាប់កសិកម្មអភិរក្ស។ ការចូលរួមរបស់ក្រុមហ៊ុនឯកជនមានសារៈសំខាន់ណាស់ ព្រោះក្រុមហ៊ុននានាក៏អាចជាចលករមួយផ្សព្វផ្សាយអំពីកសិកម្មអភិរក្ស ហើយជាអ្នកដែលអាចផ្តល់សេវាកសិកម្មអភិរក្សដល់កសិករបាន។ សូមទាក់ទងឱ្យក្រុមហ៊ុនពាក់ព័ន្ធចូលរួម ហើយបញ្ជាក់កាលបរិច្ឆេទជាមួយក្រុមហ៊ុនទាំងនោះ។ ករណីក្រុមហ៊ុនដែលស្ម័គ្រចិត្តផ្តល់គ្រឿងយន្តដើម្បីបង្ហាញក្នុងកម្មវិធី ត្រូវមានការសម្របសម្រួលរៀបចំជាមុនតាមជាក់ស្តែងផង (ឧទា. សម្របសម្រួលទំនាក់ទំនងរវាងក្រុមហ៊ុននិងម្ចាស់ទីតាំង យកគ្រឿងយន្តទៅទុកមុនថ្ងៃកម្មវិធី ។ល។)

## ៣. អញ្ជើញកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករដែលមានសក្តានុពលឱ្យមកចូលរួម

អញ្ជើញកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករដែលមានសក្តានុពល កំណត់ហើយក្នុងដំណាក់កាលទី១ ឱ្យមកចូលរួមជំនួបបង្កើតតម្រូវការនេះ។ គួរពិចារណាអំពីចម្ងាយពីកសិករដែលចូលរួមនិងសេវាករដែលចូលរួមផង ព្រោះសម្រេចសម្រួលចុងក្រោយទៅ យើងចង់ឱ្យសេវាករឃើញថាមានអ្នកត្រូវការជួលសេវាផ្សេងៗនៅក្នុងតំបន់របស់ពួកគាត់។

## ៤. ដំណើរការជំនួបបង្កើតតម្រូវការ

ដូចដែលបានពន្យល់ក្នុងផ្នែកទិដ្ឋភាពរួមមកហើយ ជំនួបនេះ ធ្វើជាពីរផ្នែកដោយឡែកពីគ្នា។ របៀបវារៈសំខាន់ៗរួមមានបទបង្ហាញអំពីកសិកម្មអភិរក្សនិងកិច្ចបង្ហាញផ្ទាល់នៅទីដាំដុះ។ បទបង្ហាញត្រូវធ្វើឱ្យសាមញ្ញងាយយល់ ដើម្បីឱ្យកសិករ សមាជិកសហគមន៍កសិកម្ម និងសេវាករចាប់បាននូវគោលគំនិតសំខាន់ៗនៃកសិកម្មអភិរក្ស។ ឯកិច្ចបង្ហាញផ្ទាល់នៅទីដាំដុះចាំបាច់ត្រូវមានដើម្បីឱ្យអ្នកចូលរួមឃើញជាក់ស្តែងនិងមានចំណាប់អារម្មណ៍ឆាប់ទទួលយកបាននូវកសិកម្មអភិរក្ស។

## ៥. ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល

ក្នុងជំនួបបង្កើតតម្រូវការនេះដែរ ត្រូវមានចំណែកពេលវេលាដើម្បីឱ្យក្រុមហ៊ុនឯកជនបានផ្សព្វផ្សាយផលិតផលរបស់ខ្លួន។ ម្យ៉ាងយើងចង់ឱ្យសេវាករដែលនឹងអាចទិញគ្រឿងយន្តឬជំណាំគម្របដីសម្រាប់កសិកម្មអភិរក្ស បានស្វែងយល់ពីផលិតផលផ្ទាល់ ម្យ៉ាងទៀតការផ្ដល់ឱកាសផ្សព្វផ្សាយនេះជាការលើកទឹកចិត្តមួយឱ្យក្រុមហ៊ុននានាគាំទ្រនិងចូលរួមជំនួបបង្កើតតម្រូវការនេះ។

## ៦. កត់ត្រាទិន្នន័យកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករចូលក្នុងប្រព័ន្ធទិន្នន័យ

ចំពោះកសិករ (ឬសហគមន៍កសិកម្ម) /សេវាករដែលមានឈ្មោះក្នុងប្រព័ន្ធហើយ ត្រូវកត់ត្រាវត្តមាននិងកំណត់សម្គាល់ផ្សេងៗចូលក្នុងប្រព័ន្ធទិន្នន័យ។ ទន្ទឹមនេះ ទោះជាអ្នកចូលរួមមានការអញ្ជើញចំឈ្មោះក្ដី បើមានកសិករ/សេវាករផ្សេងចូលរួមជាមួយគ្នាដែរ គួរចុះឈ្មោះកសិករ/សេវាករថ្មីទាំងនោះចូលក្នុងប្រព័ន្ធទិន្នន័យផង។

## ៧. កំណត់អត្តសញ្ញាណកសិករនិងសេវាករនាំមុខ

ក្រោយពីជំនួបបង្កើតតម្រូវការ ចូរទាក់ទងទៅអ្នកចូលរួមទាំងអស់ដើម្បីសាកសួរថាអ្នកណាចាប់អារម្មណ៍ចង់ប្រើសេវាកសិកម្មអភិរក្ស។ អ្នកដែលសម្រេចចិត្តទទួលសេវាកសិកម្មអភិរក្សពីដើមទីដូច្នេះ ហៅថា «កសិករនាំមុខ» (ឬ «សេវាករនាំមុខ» ព្រោះក៏អាចមានសេវាករខ្លះមានចំណាប់អារម្មណ៍ខ្លាំង ហើយប្រុងប្រៀបចេញទុនទិញគ្រឿងយន្តឆាប់ៗដែរ)។ ក្រុមការងារមន្ទីរអាចកត់ឈ្មោះទាំងកសិករនិងសេវាករនាំមុខទុកក្នុងបញ្ជីមួយ។

## ៨. ទាក់ទងក្រុមហ៊ុនដើម្បីផ្ដល់សេវាឱ្យកសិករឬសេវាករនាំមុខ

បញ្ជីដែលបានរៀបចំក្នុងជំហានមុន អាចចែករំលែកទៅក្រុមហ៊ុនពាក់ព័ន្ធតាមតម្រូវការជាក់ស្ដែង។ កិច្ចការសំខាន់ចំពោះជំហាននេះគឺសម្របសម្រួលយ៉ាងណាឱ្យក្រុមហ៊ុនពាក់ព័ន្ធផ្ដល់សេវាឱ្យកសិករនាំមុខអាចសាកល្បងអនុវត្តកសិកម្មអភិរក្សបាន។

## Tips គន្លឹះ

- ការជ្រើសរើសទីតាំងជាចំណុចយុទ្ធសាស្ត្រ។ បើអាចធ្វើនៅទីតាំងអ្នកដែលអនុវត្តកសិកម្មអភិរក្សបានលទ្ធផលល្អបាន នោះជាការណ៍ប្រសើរ។

## Tool ឯកសារ

- ឯកសារគាំទ្រ ទី៤៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញស្ដីពីកសិកម្មអភិរក្ស។




# ដំណាក់កាល ទី៣

# កិច្ចបង្ហាញទីវាល

មិត្តកសិករ

# ៤ ០៣ កិច្ចបង្ហាញនៅទីវាល

ដំណាក់កាលនេះផ្តោតលើការបង្ហាញអំពីសេវាកសិកម្មអភិរក្សដែលក្រុមហ៊ុនផ្តល់ឱ្យកសិករនាំមុខ ឱ្យកសិករដែលនៅក្បែរៗនោះបានឃើញ។ កិច្ចបង្ហាញបែបនេះ គួរធ្វើឡើងសម្រាប់គ្រប់ដំណាក់កាលទាំង៤ នៃជុំកសិកម្មអភិរក្សគឺ៖

១. ការរៀបចំដី៖ ការប្រើម៉ាស៊ីនកៀរពង្រាបដីដើម្បីធ្វើឱ្យដីស្មើ។

២. ការដាំដំណាំគម្របដី៖ ការប្រើម៉ាស៊ីនដាំមិនបាច់ភ្ជួរ ដើម្បីដាំដំណាំគម្របដី។

៣. ការពង្រាបដំណាំគម្របដីនិងដាំដំណាំប្រមូលផល៖ ការប្រើដៃរូឡកិនពង្រាប (roller crimper) (បំពាក់ទៅនឹងត្រាក់ទ័រ) ដើម្បីពង្រាបដំណាំគម្របដីនិងប្រើម៉ាស៊ីនដាំមិនបាច់ភ្ជួរដើម្បីដាំដំណាំប្រមូលផលក្នុងពេលដំណាលគ្នា។

៤. ប្រមូលផលដំណាំ៖ ប្រមូលផលនិងរៀបចំសម្រាប់ធ្វើដំណាំប្រមូលផលមួយសារទៀត ឬសម្រាប់ជុំថ្មី។

## គោលបំណង

កិច្ចបង្ហាញទាំងនេះមានគោលបំណងស្វាបស្ទង់ចំណាប់អារម្មណ៍របស់កសិករនៅតំបន់ជាមួយគ្នាក្នុងការប្រើសេវាកសិកម្មអភិរក្ស។ ម្យ៉ាងទៀត សេវាករនៃក្នុងតំបន់នោះ អាចឃើញពីទំហំតម្រូវការសេវាកសិកម្មអភិរក្ស មុននឹងសម្រេចចិត្តចំណាយទុនលើគ្រឿងយន្តនិងដំណាំគម្របដី។ សម្រាប់កិច្ចបង្ហាញដំណាក់កាលនីមួយៗ ត្រូវធ្វើតាមជំហានទី១ ដល់ទី៨។ ឯជំហានទី៩ ជាជំហានចុងក្រោយសម្រាប់ពេលបញ្ចប់កិច្ចបង្ហាញមួយជុំកសិកម្មអភិរក្សហើយ។

# ជំហាន

| | ជំហាន | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខម្នាក់ | ដើម្បីទទួលបានទីតាំងសមស្រប និងបទពិសោធកសិករនាំមុខសម្រាប់កិច្ចបង្ហាញ | កសិករនាំមុខម្នាក់យល់ព្រមឱ្យរៀបចំនៅទីតាំងរបស់គាត់។ |
| ២ | កំណត់ថ្ងៃកម្មវិធី | ដើម្បីកំណត់កាលបរិច្ឆេទសមស្របសម្រាប់ភាគីទាំងអស់ ម្បីកំណត់កាលបរិច្ឆេទសមស្របសម្រាប់ភាគីទាំងអស់ | ភាគីទាំងអស់ព្រមព្រៀងលើកាលបរិច្ឆេទ។ |
| ៣ | សម្របសម្រួលប្រុងប្រៀបគ្រឿងយន្ត | ដើម្បីធានាថាដៃគូឯកជនត្រៀមរួចរាល់ក្នុងការបង្ហាញគ្រឿងយន្ត | ដៃគូឯកជនប្រុងប្រៀបរួចរាល់។ |
| ៤ | អញ្ជើញកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករដែលមានចំណាប់អារម្មណ៍ ៦០នាក់ | ដើម្បីឱ្យពួកគាត់ចូលរួមកិច្ចបង្ហាញ | កសិករ/សេវាករ ៦០នាក់បញ្ជាក់ការចូលរួម។ |
| ៥ | រៀបចំទីតាំងត្រៀមសម្រាប់កម្មវិធី | ដើម្បីឱ្យទីតាំងរួចរាល់មុនកម្មវិធី | ផ្នែកចាំបាច់ត្រូវបានដំឡើងនិងពិនិត្យបញ្ជាក់។ |
| ៦ | ដំណើរការកិច្ចបង្ហាញតាមដំណាក់កាលកសិកម្មអភិរក្ស | ដើម្បីជំរុញកសិករកាន់តែច្រើនឱ្យអនុវត្តកសិកម្មអភិរក្សនិងបង្ហាញសេវាករថាមានតម្រូវការគ្រឿងយន្តកសិកម្មអភិរក្សក្នុងតំបន់គាត់ | កសិករកាន់តែច្រើនចាប់អារម្មណ៍អនុវត្តកសិកម្មអភិរក្ស។ សេវាករមានបំណងចំណាយទុនលើគ្រឿងយន្ត។ |
| ៧ | ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល | ដើម្បីផ្តល់ឱកាសឱ្យក្រុមហ៊ុនផ្សព្វផ្សាយផលិតផលនិងសេវាកសិកម្មអភិរក្ស | ផលិតផលនិងសេវាកសិកម្មអភិរក្សត្រូវបានបង្ហាញ។ |
| ៨ | កត់ត្រាទិន្នន័យកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករចូលក្នុងប្រព័ន្ធទិន្នន័យ | ដើម្បីកត់ត្រាព័ត៌មានកសិករ/សេវាករ និងការប្រែប្រួលឥរិយាបថចំពោះការធ្វើកសិកម្មអភិរក្ស | ព័ត៌មានកសិករ/សេវាករថ្មីត្រូវបានកត់ត្រា។ ព័ត៌មានកសិករ/សេវាករពីមុនត្រូវបានធ្វើបច្ចុប្បន្នភាព។ |
| ៩ | ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករតាមមធ្យោបាយទាក់ទងនានា | ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករតាមមធ្យោបាយទាក់ទងនានា | កសិករទទួលបានជំនួយបច្ចេកទេសគ្រប់គ្រាន់។ |

## សេចក្តីណែនាំលើជំហាននីមួយៗ

### ១. ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខម្នាក់

កិច្ចបង្ហាញនីមួយៗត្រូវរៀបចំនៅទីដាំដុះរបស់កសិកម្មនាំមុខម្នាក់ ដើម្បីឱ្យកសិករនាំមុខនោះបានចែករំលែកពីបទពិសោធរបស់ខ្លួនផង។ នៅពេលជ្រើសរើសកសិករនាំមុខឬទីតាំង គួរពិចារណាលើកត្តាមួយចំនួនដូចជា លទ្ធផលដាំដុះរបស់កសិករនោះ ចំនួនកសិករនិងសេវាករដែលនៅក្បែរ និងភាពងាយស្រួលទៅវិញទៅមកជាដើម។

### ២. កំណត់ថ្ងៃកម្មវិធី

ដើម្បីបង្ហាញការប្រើប្រាស់គ្រឿងយន្តបាន តោងជ្រើសរើសថ្ងៃកម្មវិធីដោយផ្អែកលើរដូវនៃដំណាំ។ ម្យ៉ាងទៀត ត្រូវរំលែកយកថ្ងៃដែលកសិករនិងសេវាករជាអ្នកចូលរួមអាចចូលរួមបានភាគច្រើនលើសលប់ ហើយចាំបាច់ត្រូវតែជាថ្ងៃដែលដៃគូឯកជនអាចចូលរួមបានផងដែរ។

### ៣. សម្របសម្រួលប្រុងប្រៀបគ្រឿងយន្ត

ដើម្បីកិច្ចបង្ហាញនីមួយៗបានជោគជ័យ ត្រូវមានកិច្ចសហការរលូនរវាងដៃគូឯកជននិងកសិករនាំមុខជាម្ចាស់ទីតាំងកម្មវិធី។ ដូច្នេះ គួរផ្តល់ឱ្យដៃគូឯកជនឱ្យបានលម្អិតនិងច្បាស់លាស់នូវព័ត៌មានអំពីកម្មវិធី រួមមានចំណុចទីតាំងកម្មវិធី ទំហំដីដាំដុះ ស្ថានភាពដី ព្រមទាំងរបៀបវារៈ។ គួរសម្របសម្រួលឱ្យមានការរៀបទុកជាមុន តាមការចាំបាច់ជាក់ស្តែង។

### ៤. អញ្ជើញកសិករ(ឬសហគមន៍កសិកម្ម)និងសេវាករដែលមានចំណាប់អារម្មណ៍ ៦០នាក់

កសិករ (ឬសហគមន៍កសិកម្ម) និងសេវាករដែលមានចំណាប់អារម្មណ៍ទាំង ៦០នាក់ គួរយកចេញពីអ្នកដែលបានចូលរួមក្នុងជំនួបបង្កើតតម្រូវការ។ ចំណុចសំខាន់គឺធ្វើយ៉ាងណាឱ្យកសិករ/សេវាករ ៦០នាក់ ដដែលនេះចូលរួមកិច្ចបង្ហាញទាំង៤លើក។

### ៥. រៀបចំទីតាំងត្រៀមសម្រាប់កម្មវិធី

នៅពេលអ្នកចូលរួមឃើញការដាំដុះតាមបែបកសិកម្មអភិរក្សជាក់ស្តែងតាមដំណាក់កាលទាំង៤ ពួកគាត់នឹងងាយទទួលយកទៅអនុវត្តដែរ។ ដូច្នេះហើយ ទីតាំងដាំដុះរបស់កសិករនាំមុខស្ម័គ្រចិត្តនោះ គួរប្រុងប្រៀបឱ្យបានម៉ត់ចត់បំផុតសម្រាប់ផ្នែកបង្ហាញគ្រឿងយន្តផង សម្រាប់ការទាក់ទងសួរនាំទូទៅផង។ ត្រូវមានរោងឬម្លប់និងកៅអីនៅក្បែរទីតាំងដាំដុះនោះ ហើយត្រូវរៀបចំនិងត្រួតពិនិត្យប្រព័ន្ធសំឡេងផង។

### ៦. ដំណើរការកិច្ចបង្ហាញតាមដំណាក់កាលកសិកម្មអភិរក្ស

កិច្ចបង្ហាញទាំង៤លើក បង្ហាញលទ្ធផលជាក់ស្តែងនៃការធ្វើកសិកម្មអភិរក្ស ហើយមានគោលបំណងរួមគឺការជំរុញឱ្យកសិករកាន់តែច្រើនអនុវត្តកសិកម្មអភិរក្សនិងបង្ហាញសេវាករថាមានតម្រូវការគ្រឿងយន្តក្នុងទីតាំងរបស់គាត់។ កិច្ចបង្ហាញតាមដំណាក់កាលនីមួយៗ ជាឱកាសល្អសម្រាប់ពន្យល់ចំណុចបច្ចេកទេសលម្អិតនិងបច្ចេកវិទ្យាដែលសមស្របទៅតាមដំណាក់កាលនោះរៀងៗគ្នា។

### ៧. ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល

ក្នុងកិច្ចបង្ហាញនីមួយៗ គួរមានចំណែកពេលវេលាដើម្បីឱ្យដៃគូឯកជនបានផ្សព្វផ្សាយផលិតផលរបស់ខ្លួន។ កិច្ចបង្ហាញទាំងនេះជាឱកាសល្អសម្រាប់ឱ្យសេវាករដែលនឹងអាចទិញគ្រឿងយន្តឬដំណាំគម្របដីសម្រាប់កសិកម្មអភិរក្ស បានស្វែងយល់ពីផលិតផលទាំងនេះផ្ទាល់។

## ៨.	កត់ត្រាទិន្នន័យកសិករនិងសេវាករចូលក្នុងប្រព័ន្ធទិន្នន័យ

ដូចក្នុងដំណាក់កាលទី២ដែរ ចំពោះកសិករ (ឬសហគមន៍កសិកម្ម) /សេវាករដែលមានឈ្មោះក្នុងប្រព័ន្ធហើយ ត្រូវកត់ត្រាវត្តមាននិងកំណត់សម្គាល់ផ្សេងៗចូលក្នុងប្រព័ន្ធទិន្នន័យ។ ប្រសិនបើចៃដន្យមានកសិករ/សេវាករផ្សេងចូលរួមជាមួយគ្នាដែរ គួរចុះឈ្មោះកសិករ/សេវាករថ្មីទាំងនោះនិងចំណុចកត់សម្គាល់ពាក់ព័ន្ធ ចូលក្នុងប្រព័ន្ធទិន្នន័យផង។

## ៩.	ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករតាមមធ្យោបាយទាក់ទងនានា

ក្រោយពីបញ្ចប់កិច្ចបង្ហាញគ្រប់៤ដំណាក់កាលហើយ ក្រុមការងារមន្ទីរគួរបង្កើតច្រកទំនាក់ទំនងមួយដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់កសិករ ក្នុងករណីគាត់មានមន្ទិលឬបញ្ហាប្រឈមអ្វីពាក់ព័ន្ធនឹងដំណាក់កាលទាំង៤នៃជុំកសិកម្មអភិរក្ស។

## Tips គន្លឹះ

ដើម្បីទាក់ទាញឱ្យកសិករច្រើនជាងមុនអនុវត្តកសិកម្មអភិរក្ស បទបង្ហាញក្នុងកិច្ចបង្ហាញនីមួយៗត្រូវគូសបញ្ជាក់ឱ្យច្បាស់អំពីគុណប្រយោជន៍នៃកសិកម្មអភិរក្សដល់ទាំងកសិករនិងសេវាករ។ ចំពោះសេវាករ វិធីល្អបំផុតគឺគណនាចំណាយ/ចំណេញជូនគាត់មើល ដើម្បីឱ្យឃើញថាគួរចេញទុនទិញគ្រឿងយន្តនិងបច្ចេកវិទ្យាផ្សេងៗឬទេ។

## Tool ឯកសារ

ឯកសារគាំទ្រទី៥៖ មធ្យោបាយទាក់ទងសម្រាប់ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករ។



# ដំណាក់កាល ទី៤
# កិច្ចបង្ហាញពាណិជ្ជកម្ម

# ០៤ កិច្ចបង្ហាញពាណិជ្ជកម្ម

ក្នុងដំណាក់កាលនេះ ក្រុមការងារមន្ទីរទាក់ទងជាមួយនឹងកសិករនាំមុខមួយរូបដើម្បីរៀបចំកិច្ចបង្ហាញទ្រង់ទ្រាយធំ ដោយមានការគាំទ្រផ្នែកគ្រឿងយន្តពីក្រុមហ៊ុនឯកជន។ ដូចដំណាក់កាលទី៣ដែរ ដំណាក់កាលនេះមានបំណងឱ្យមានកសិករកាន់តែច្រើនទទួលយកកសិកម្មអភិរក្សទៅអនុវត្ត។ តែ ដំណាក់កាលនេះប្លែកពីដំណាក់កាលមុនត្រង់ពីរបែប។ ទីមួយ ការរៀបចំលើកនេះមានលក្ខណៈធំជាង (មានអ្នកចូលរួមច្រើនជាង)។ ទីពីរ ដំណាក់កាលនេះបង្វែរចំណុចផ្ដោតពីព័ត៌មានបច្ចេកទេសនៃជុំកសិកម្មអភិរក្សទៅផ្ដោតលើគ្រឿងយន្តនិងបច្ចេកវិទ្យានានាតែម្ដង។

## គោលបំណង

កិច្ចបង្ហាញទ្រង់ទ្រាយធំមានបំណងផ្សព្វផ្សាយកសិកម្មអភិរក្សទៅកាន់កសិករឱ្យកាន់តែច្រើន ជាពិសេសកសិករនៅក្នុងតំបន់ជាមួយនឹងកសិករនាំមុខដែលជោគជ័យ។ បន្ថែមពីលើនេះ កិច្ចបង្ហាញនេះជាឱកាសល្អឱ្យក្រុមហ៊ុនឯកជនបង្ហាញផលិតផលខ្លួននិងបង្ហាញកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនដែលមានបទពិសោធផ្ដល់សេវាកសិកម្មមកកាន់តំបន់នេះ។

# ជំហាន

| | ជំហាន | គោលបំណង | លទ្ធផល |
| --- | --- | --- | --- |
| ១ | ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខជោគជ័យម្នាក់ | ដើម្បីទទួលបានទីតាំងសមស្រប និងកសិករដែលមានបទពិសោធជោគជ័យជាដៃគូ | កសិករនាំមុខជោគជ័យម្នាក់យល់ព្រមផ្តល់ទីតាំងនិងពេលវេលាឱ្យរៀបចំកម្មវិធី។ |
| ២ | កំណត់ថ្ងៃកម្មវិធី | ដើម្បីកំណត់កាលបរិច្ឆេទសមស្រប សម្រាប់ភាគីទាំងអស់ | ភាគីទាំងអស់ព្រមព្រៀងលើកាលបរិច្ឆេទ។ |
| ៣ | សម្របសម្រួលប្រុងប្រៀបគ្រឿងយន្ត | ដើម្បីធានាថាក្រុមហ៊ុនឯកជនត្រៀមរួចរាល់ក្នុងការបង្ហាញគ្រឿងយន្ត | ក្រុមហ៊ុនឯកជនប្រុងប្រៀបរួចរាល់។ |
| ៤ | អញ្ជើញកសិករថ្មី ១៤០នាក់ | ដើម្បីឱ្យពួកគាត់ចូលរួមកិច្ចបង្ហាញ | កសិករនៅជុំវិញ ១៤០នាក់បញ្ជាក់ការចូលរួម។ |
| ៥ | រៀបចំទីតាំងនិងត្រៀមលំដាប់លំដោយសម្រាប់កម្មវិធី | ដើម្បីឱ្យកម្មវិធីដំណើរការទៅរលូន | ទីតាំងនិងផ្នែកចាំបាច់ ត្រូវបានរៀបចំរួចរាល់។ |
| ៦ | ដំណើរការកិច្ចបង្ហាញទ្រង់ទ្រាយធំ | ដើម្បីផ្សព្វផ្សាយកសិកម្មអភិរក្សនិងបទពិសោធជោគជ័យរបស់កសិករនាំមុខដល់កសិករនៅតំបន់ជុំវិញ។ | កសិករកាន់តែច្រើនយល់ដឹង និងកសិករមួយចំនួនចាប់អារម្មណ៍ធ្វើកសិកម្មអភិរក្ស។ |
| ៧ | ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល | ដើម្បីផ្តល់ឱកាសឱ្យក្រុមហ៊ុនផ្សព្វផ្សាយផលិតផលនិងសេវាកសិកម្មអភិរក្ស | ផលិតផលនិងសេវាកសិកម្មអភិរក្សត្រូវបានបង្ហាញ។ |

មិត្តកសិករ

## សេចក្តីណែនាំលើជំហាននីមួយៗ

### ១. ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខជោគជ័យម្នាក់

កសិករនាំមុខជោគជ័យ ព្រមទាំងទីតាំងដាំដុះដែលបង្ហាញពីលទ្ធផលល្អ ដើរតួសំខាន់ណាស់ក្នុងកិច្ចបង្ហាញទ្រង់ទ្រាយធំនេះ ព្រោះដើម្បីឱ្យកសិករផ្សេងទៀតទទួលយកបច្ចេកវិទ្យាថ្មី (កសិកម្មអភិរក្ស) ទាមទារឱ្យមានសក្ខីភាពពីអ្នកអនុវត្តមុន។ កសិករនាំមុខជោគជ័យនេះក៏អាចក្លាយជាអ្នកប្រឹក្សាយោបល់ជូនកសិករដទៃទៀតដែលនៅជុំវិញដែរ។ ទន្ទឹមនឹងកត្តាជោគជ័យនេះ ក៏គួរពិចារណាពីកត្តាទីតាំងឱ្យងាយស្រួលធ្វើដំណើរសម្រាប់អ្នកចូលរួមដែរ។

### ២. កំណត់ថ្ងៃកម្មវិធី

ត្រូវជ្រើសរើសយកកាលបរិច្ឆេទដែលសមស្របសម្រាប់កសិករម្ចាស់ទីតាំងផងនិងខាងក្រុមហ៊ុនឯកជននានាដែលចូលរួមផង។ ប្រាកដណាស់ ក៏ត្រូវជ្រើសយកថ្ងៃណាដែលកសិករនិងសេវាករភាគច្រើនមានពេលចូលរួមដែរ ព្រោះពួកគាត់ជាក្រុមគោលដៅដែលត្រូវទទួលចំណេះដឹងអំពីកសិកម្មអភិរក្សទៅអនុវត្តនិងផ្សព្វផ្សាយបន្ត។

### ៣. សម្របសម្រួលប្រុងប្រៀបគ្រឿងយន្ត

ដើម្បីកិច្ចបង្ហាញនេះបានជោគជ័យ ត្រូវមានកិច្ចសហការរលូនរវាងដៃគូឯកជននិងកសិករនាំមុខជាម្ចាស់ទីតាំង។ ដូច្នេះ គួរផ្តល់ឱ្យដៃគូឯកជនឱ្យបានលម្អិតនិងច្បាស់លាស់នូវព័ត៌មានអំពីកម្មវិធី រួមមានចំណុចទីតាំងកម្មវិធីនិងចំណែកពេលសម្រាប់ក្រុមហ៊ុននីមួយៗបង្ហាញផលិតផលរបស់ខ្លួនជាអាទិ៍។ គួរសម្របសម្រួលឱ្យមានការរៀបចំទុកជាមុន តាមការចាំបាច់ជាក់ស្តែង។

### ៤. អញ្ជើញកសិករថ្មី ១៤០នាក់

កសិករទាំង ១៤០នាក់នេះ គួរជ្រើសរើសពីកសិករដែលនៅក្បែរឬនៅតំបន់ជុំវិញកសិករនាំមុខជោគជ័យ ដើម្បីឱ្យពួកគាត់ឃើញថាកសិករនៅជិតគាត់បានសាកល្បងប្រើវិធីសាស្ត្រដាំដុះថ្មី ហើយបានទទួលផលល្អប្រសើរដោយមានប្រសិទ្ធផលជាងមុននិងជាវិធីសាស្ត្រដាំដុះប្រកបដោយចីរភាព។

### ៥. រៀបចំទីតាំងនិងត្រៀមលំដាប់លំដោយសម្រាប់កម្មវិធី

ការរៀបចំត្រៀមជាទូទៅប្រហាក់ប្រហែលគ្នានឹងកិច្ចបង្ហាញតាមដំណាក់កាលនៃជុំកសិកម្មអភិរក្សដែរ តែប្លែកត្រង់ថាមានអ្នកចូលរួមច្រើនជាងមុននិងកម្មវិធីផ្តោតទៅលើគ្រឿងយន្តនិងបច្ចេកវិទ្យានានា។ ដូច្នេះ ក្រុមការងាររៀបចំកម្មវិធី ត្រូវប្រុងប្រៀបទៅតាមទំហំនិងបែបបទនេះដែរ ដូចជាត្រូវរៀបចំឱ្យមានទីធ្លាគ្រប់គ្រាន់និងមានលំដាប់លំដោយ សម្រាប់ឱ្យអ្នកចូលពិនិត្យមើលនិងសាកល្បងផលិតផលផ្សេងៗ ពិនិត្យមើលដំណាំឬផ្ទៃដីដាំដុះនិងសម្រាកសម្រួលឥរិយាបថ ឬជជែកផ្លាស់ប្តូរយោបល់គ្នាដោយក្រុមៗជាដើម។។

### ៦. ដំណើរការកិច្ចបង្ហាញទ្រង់ទ្រាយធំ

ដំណើរការកម្មវិធីត្រូវមានបីចំណុចជាសំខាន់គឺ (១) បទបង្ហាញសង្ខេបអំពីកសិកម្មអភិរក្ស (២) គ្រឿងចក្រច្រើនប្រភេទសម្រាប់អ្នកចូលរួមបានស្គាល់និងអាចសាកល្បងប្រើប្រាស់ និង (៣) អ្នកផ្តល់ព័ត៌មានឬប្រភពព័ត៌មានផ្សេងៗ ដើម្បីឱ្យកសិករដឹងថាត្រូវទៅរកសេវាកសិកម្មអភិរក្សនៅកន្លែងណា ដោយរបៀបណា។

### ៦. ឱ្យក្រុមហ៊ុនផ្សាយពីផលិតផល

កិច្ចបង្ហាញទ្រង់ទ្រាយធំនេះ បើកឱកាសឱ្យក្រុមហ៊ុនផ្សព្វផ្សាយផលិតផលរបស់ខ្លួន។ កិច្ចបង្ហាញទាំងនេះជាឱកាសល្អសម្រាប់ឱ្យសេវាករដែលនឹងអាចទិញគ្រឿងយន្តឬដំណាំគម្របដីសម្រាប់កសិកម្មអភិរក្ស បានស្វែងយល់ពីផលិតផលទាំងនេះផ្ទាល់។

មិត្តកសិករ

## Tips គន្លឹះ

ក្នុងដំណើរការកម្មវិធី គួរព្យាយាមសង្កេតនិងកត់ត្រាអំពីចំណាប់អារម្មណ៍របស់ក្រុមកសិករដែលចូលរួមទាំងអស់។ ក្រោយមក ក្រុមការងារអាចធ្វើបញ្ជីកសិករដែលមានបំណងចង់សាកល្បងប្រើសេវាកសិកម្មអភិរក្សឬឈានដល់ទិញគ្រឿងយន្តកសិកម្មអភិរក្សផង។ បញ្ជីនេះអាចធ្វើឱ្យក្រុមហ៊ុនពាក់ព័ន្ធតាមការចាំបាច់។



# ដំណាក់កាល ទី៥

# កិច្ចប្រជុំប្រចាំឆ្នាំ

# ៤.០៦ កិច្ចប្រជុំប្រចាំឆ្នាំ

ដំណាក់កាលនេះជាឱកាសដែលដៃគូទាំងអស់ រួមមានរដ្ឋបាលខេត្ត នាយកដ្ឋានថ្នាក់ជាតិទាំងបី និងដៃគូឯកជនជួបជុំគ្នាដើម្បីស្តាប់មន្ទីរក.ស.ក. រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តគំរូមិត្តកសិករ។

## គោលបំណង

ដើម្បីបង្ហាញវឌ្ឍនភាពនៃការអនុវត្តគំរូមិត្តកសិករនិងអញ្ជើញដៃគូថ្មី ជាពិសេសគឺក្រុមហ៊ុនឯកជនថ្មីៗ ឱ្យចូលរួមក្នុងការអនុវត្ត។

## ជំហាន

| | ជំហាន | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខជោគជ័យម្នាក់ | ដើម្បីតំណាងស្ថាប័ន/អង្គភាពនីមួយៗចូលរួម | ការបញ្ជាក់ចូលរួមពីដៃគូទាំងអស់ |
| ២ | ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខជោគជ័យម្នាក់ | ដើម្បីបង្ហាញសមិទ្ធផលនៃគំរូមិត្តកសិករ, ទាក់ទាញក្រុមហ៊ុនឯកជនថ្មីៗចូលរួម, និងទទួលអនុសាសន៍សម្រាប់កែលម្អការអនុវត្តឆ្នាំក្រោយ | ដៃគូនានាបានឃើញពីសមិទ្ធផល។ ក្រុមការងារទទួលបានអនុសាសន៍សម្រាប់អនុវត្តឆ្នាំក្រោយ។ |

## សេចក្ដីណែនាំលើជំហាននីមួយៗ

### ១. អញ្ជើញរដ្ឋបាលខេត្ត នាយកដ្ឋានថ្នាក់ជាតិទាំងបី និងក្រុមហ៊ុនចូលរួម

គួរអញ្ជើញបុគ្គលសំខាន់ៗ មានដូចជាថ្នាក់ដឹកនាំរដ្ឋបាលខេត្តនិងនាយកដ្ឋានថ្នាក់ជាតិទាំងបីដែលជាទីប្រឹក្សា មកចូលរួមកិច្ចប្រជុំនេះ។ ទន្ទឹមនេះ គ៏គួរស្វែងរកនិងអញ្ជើញក្រុមហ៊ុនផ្សេងៗដែលមានសក្ដានុពលគាំទ្រការអនុវត្តគំរូនេះ ឱ្យមកចូលរួមប្រជុំផងដែរ។

### ២. ដំណើរការប្រជុំប្រចាំឆ្នាំ

ក្រៅពីបង្ហាញវឌ្ឍនភាពការងារហើយ កិច្ចប្រជុំនេះក៏ជាឱកាសទាក់ទាញក្រុមហ៊ុនថ្មីឱ្យក្លាយជាដៃគូអនុវត្តគំរូនេះរួមគ្នាដែរ។ ដូច្នេះ សមិទ្ធផលការងារនានាអាចចាត់ទុកជាតឹកតាងសម្រាប់គូសបញ្ជាក់អត្ថប្រយោជន៍ដែលក្រុមហ៊ុនឯកជនអាចទទួលបានពីការចូលរួមអនុវត្តគំរូនេះ។

## Tips គន្លឹះ

លើកឡើងអំពីសមិទ្ធផលការងារក្នុងបរិការណ៍នៃគោលដៅថ្នាក់ខេត្តនិងថ្នាក់ជាតិ។ ប្រធានមន្ទីរ ក.ស.ក. ក៏អាចលើកឡើងអំពីសមិទ្ធផលទាំងនេះនៅសន្និបាតប្រចាំឆ្នាំរបស់ក្រសួងបានដែរ។

## Tool ឯកសារ

ឯកសារគាំទ្រ ទី៥៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំ។



# ដំណាក់កាល ទី៦

# ជំនួបផ្សព្វផ្សាយជាមួយ វិស័យឯកជន

# ឧ ០៦ ជំនួបផ្សព្វផ្សាយជាមួយវិស័យឯកជន

ដំណាក់កាលនេះផ្តោតលើការទាក់ទាញក្រុមហ៊ុនឯកជនថ្មីចូលរួមក្នុងការអនុវត្តគំរូមិត្តកសិករ ដោយចាប់ផ្តើមពីការកំណត់អត្តសញ្ញាណក្រុមហ៊ុនដែលមានសក្តានុពល រួចអញ្ជើញតំណាងក្រុមហ៊ុននោះទៅធ្វើទស្សនកិច្ចដល់ទីតាំងអនុវត្តដើម្បីឃើញសមិទ្ធផលការងារជាក់ស្តែង។

## គោលបំណង

ដើម្បីបង្កើនចំនួនក្រុមហ៊ុនដែលចូលរួមគាំទ្រការអនុវត្តគំរូមិត្តកសិករ ជាពិសេសសម្រាប់ជុំបន្ទាប់។

## ជំហាន

| ជំហាន | | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | ព្រមព្រៀងទីតាំងជាមួយនឹងកសិករនាំមុខជោគជ័យម្នាក់ | ដើម្បីតំណាងស្ថាប័ន/អង្គភាពនីមួយៗចូលរួម | ដើម្បីតំណាងស្ថាប័ន/អង្គភាពនីមួយៗចូលរួម |
| ២ | អញ្ជើញក្រុមហ៊ុនធ្វើទស្សនកិច្ច | ដើម្បីបង្ហាញពីសមិទ្ធផលការងារនៅទីតាំងជាំដុះជាក់ស្តែងនិងជំរុញឱ្យក្រុមហ៊ុននោះចូលរួមអនុវត្តគំរូមិត្តកសិករ | ក្រុមហ៊ុនបញ្ជាក់ការចុះទស្សនកិច្ច។ |

## សេចក្តីណែនាំលើជំហាននីមួយៗ

### ១. កំណត់អត្តសញ្ញាណក្រុមហ៊ុនមានសក្តានុពល

ការស្វែងរកដៃគូឯកជនថ្មីៗមានសារៈសំខាន់ណាស់ក្នុងការបន្តអនុវត្តគំរូនេះ និងបញ្ជ្រាបកសិកម្មអភិរក្សចូលទីផ្សារឱ្យកាន់តែទូលំទូលាយឡើង។ ដើម្បីកំណត់ក្រុមហ៊ុនដែលមានសក្តានុពលជាដៃគូ ចូរពិនិត្យលក្ខណៈសម្បត្តិក្រុមហ៊ុន រួមមានប្រភេទមុខជំនួញ ភាពពាក់ព័ន្ធនឹងវិស័យកសិកម្ម ព្រមទាំងអត្ថប្រយោជន៍ដែលក្រុមហ៊ុននោះអាចទទួលបានពីការចូលរួមអនុវត្តគំរូ ។ល។

### ២. អញ្ជើញក្រុមហ៊ុនធ្វើទស្សនកិច្ច

កំណត់ថ្ងៃហើយសាកសួរថាតំណាងក្រុមហ៊ុនមានពេលចូលរួមឬទេ។

មិត្តកសិករ

## Tips គន្លឹះ

- ពេលទស្សនកិច្ច គួរនាំតំណាងក្រុមហ៊ុនទៅទីតាំងដាំដុះរបស់កសិករជុំមុនដែលទទួលបានជោគជ័យ។

- ពេលទស្សនកិច្ចក៏ជាឱកាសមួយសម្រាប់ឱ្យក្រុមហ៊ុនជួបជាមួយនឹងកសិករដែលមានចំណាប់អារម្មណ៍ថ្មីៗ ព្រមទាំងសេវាករនៅក្បែរៗគ្នា ដើម្បីក្រុមហ៊ុនទទួលបានព័ត៌មានអំពីតម្រូវការគ្រឿងយន្តឬការប្រើដំណាំគម្របដីរបស់កសិករ។

## Tool ឯកសារ

- ឯកសារគាំទ្រទី១៖ បញ្ជីសំណួរសម្រាប់សួរមេឃុំ មេភូមិ។

- ឯកសារគាំទ្រទី២៖ បញ្ជីសំណួរសម្រាប់សម្ភាសកសិករ។

- ឯកសារគាំទ្រទី៣៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញស្ដីពីកសិកម្មអភិរក្ស។

- ឯកសារគាំទ្រទី៤៖ មធ្យោបាយទាក់ទងសម្រាប់ផ្ដល់ការគាំទ្របច្ចេកទេសដល់កសិករ។

- ឯកសារគាំទ្រទី៥៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំ។



# ឧបសម្ព័ន្ធ

# ឯកសារគាំទ្រទី ១៖ បញ្ជីសំណួរសម្រាប់សួរមេឃុំ មេភូមិ

*អំពីកសិករ (ឬសហគមន៍កសិកម្ម) ក្នុងឃុំ/ភូមិ៖*

១. ក្នុងឃុំ/ភូមិនេះមានកសិករប៉ុន្មាននាក់?

______________________________

២. ក្នុងចំណោមកសិករទាំងនោះ តើមានប៉ុន្មាននាក់ដែលទំនងអាចឱ្យគាត់អនុវត្តកសិកម្មអភិរក្សបាន?

______________________________

៣. តើកសិករក្នុងឃុំ/ភូមិភាគច្រើនដាំដំណាំអ្វី?

គូសដំណាំដែលមានទាំងអស់។

- ☐ ស្រូវ
- ☐ ពោត
- ☐ ស្វាយចន្ទី
- ☐ ដំឡូងមី
- ☐ កៅស៊ូ
- ☐ ផ្សេងទៀត៖ ______________________________

៤. លេខទំនាក់ទំនងនិងអាសយដ្ឋានកសិករ៖

| ឈ្មោះ | ភេទ | មុខដំណាំ | ផ្ទៃដីដាំដុះ (ហិត) | លេខទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

*អំពីសេវាករក្នុងឃុំ/ភូមិ៖*

១. ក្នុងឃុំ/ភូមិនេះមានសេវាករប៉ុន្មាននាក់?

______________________________

២. លេខទំនាក់ទំនងនិងអាសយដ្ឋានសេវាករ៖

| ឈ្មោះ | ម៉ាកត្រាក់ទ័រ | អានុភាពត្រាក់ទ័រ (កម្លាំងសេះ) | ផ្ទៃដីដាំដុះ (ហិត) | លេខទូរស័ព្ទ | អាសយដ្ឋាន |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

# ឯកសារគាំទ្រ ទី២ ៖ បញ្ជីសំណួរសម្រាប់សម្ភាសកសិករ (ឬសហគមន៍កសិកម្ម)

១.	ឈ្មោះ

______________________

២.	ភេទ

*គូសយកតែមួយ*

- ស្រី
- ប្រុស
- សុំមិននិយាយ
- ផ្សេងទៀត៖ ______________________

៣.	អាយុ

______________________

៤.	លេខទូរស័ព្ទ

______________________

៥.	អាសយដ្ឋាន

______________________

៦.	ទំហំដីដាំដុះសរុប

*គូសយកតែមួយ*

- តិចជាង ១ ហិកតា
- ១ ហិកតា - ៣ ហិកតា
- ៤ ហិកតា - ៦ ហិកតា
- ៧ ហិកតា - ១០ ហិកតា
- ១១ ហិកតា - ១៥ ហិកតា
- ១៦ ហិកតា - ២០ ហិកតា
- លើសពី ២០ ហិកតា

៧.	មុខដំណាំ៖

*គូសដំណាំដែលមានទាំងអស់។*

| | < ១ ហត | ១ ហត– ៣ ហត | ៤ ហត- ៦ហត | ៧ ហត- ១០ ហត | ១១ ហត- ១៥ ហត | ១៦ ហត- ២០ ហត | > ២០ ហត |
|---|---|---|---|---|---|---|---|
| ស្រូវ | | | | | | | |
| ពោត | | | | | | | |
| ស្វាយចន្ទី | | | | | | | |
| ដំឡូងមី | | | | | | | |
| កៅស៊ូ | | | | | | | |
| ដទៃទៀត | | | | | | | |

៨. តើការដាំដំណាំទាំងនេះ ជួបប្រទះនឹងបញ្ហាអ្វីខ្លះ?

*គូសប្រអប់ទាំងអស់ដែលពាក់ព័ន្ធ។*

| | សត្វចង្រៃ | ជម្ងឺដំណាំ | ពលកម្ម | ធាតុអាកាស | ហិរញ្ញវត្ថុ | តម្លៃដំណាំ | ថ្លៃដើម (ជីនិងថ្នាំ) |
|---|---|---|---|---|---|---|---|
| ស្រូវ | | | | | | | |
| ពោត | | | | | | | |
| ស្វាយចន្ទី | | | | | | | |
| ដំឡូងមី | | | | | | | |
| កៅស៊ូ | | | | | | | |
| ដទៃទៀត | | | | | | | |

៩. តើអ្នកធ្លាប់ឮពីកសិកម្មអភិរក្សឬទេ?

*គូសយកតែមួយ*

- ធ្លាប់
- មិនធ្លាប់

១០. តើអ្នកចាប់អារម្មណ៍អនុវត្តកសិកម្មអភិរក្សឬទេ?

*គូសយកតែមួយ*

- ចាប់អារម្មណ៍
- មិនចាប់អារម្មណ៍

# ឯកសារគាំទ្រ ទី៣៖ បញ្ជីសំណួរសម្រាប់សម្ភាសសេវាករ

មិត្តកសិករ

១. ឈ្មោះ

______________________________

២. ភេទ

*គូសយកតែមួយ*

- ស្រី
- ប្រុស
- សុំមិននិយាយ
- ផ្សេងទៀត៖

៣. អាយុ

______________________________

៤. លេខទូរស័ព្ទ

______________________________

៥. អាសយដ្ឋាន

______________________________

៦. បច្ចុប្បន្ននេះ តើអ្នកមានម៉ាស៊ីនប្រភេទណាខ្លះ?

*គូសយកទាំងអស់ដែលមាន*

- ត្រាក់ទ័រ
- ឧបករណ៍ភ្ជាប់
- ផ្សេងទៀត៖ ______________________________

៧. ម៉ាស៊ីនមួយមុខៗមានចំនួនប៉ុន្មាន?

______________________________

៨. តើអ្នកមានបំណងទិញត្រាក់ទ័រនិងឧបករណ៍ភ្ជាប់ថ្មីដែរឬទេ?

*គូសយកតែមួយ*

- មានបំណង
- គ្មានទេ

មិត្តកសិករ

# ឯកសារគាំទ្រ ទី៤៖ មធ្យោបាយទាក់ទងសម្រាប់ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករ

- ខិត្តប័ណ្ណ
- តាមទូរស័ព្ទ
- តាមកម្មវិធីទូរស័ព្ទ តេលេក្រាម (Telegram)
- តាមក្រុមឆ្លើយឆ្លងសាររបស់ហ្វេសប៊ុក គឺកម្មវិធីមែសេ្សងចឺ (Messenger Group)

# ឯកសារគាំទ្រ ទី៥៖ ចំណុចដែលត្រូវមានក្នុងបទបង្ហាញ សម្រាប់កិច្ចប្រជុំប្រចាំឆ្នាំ

១. វឌ្ឍនភាពនៃការអនុវត្តគំរូមិត្តកសិកររបស់មន្ទីរក.ស.ក.

២. សមិទ្ធផលទទួលបានពីការអនុវត្ត

៣. ទាំងអស់នេះមានសារៈប្រយោជន៍យ៉ាងណាចំពោះផ្នែកឯកជន? ហេតុអ្វីបានជាក្រុមហ៊ុនឯកជនគួរគាំទ្រការអនុវត្តគំរូនេះ